ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមិថុនា និងទិសដៅការងារខែកក្កដា ឆ្នាំ២០១៨

**សេចក្តីផ្តើម:**

នៅក្នុងខែមិថុនានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោម៖

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា:

### ១.មុខងារនីតិកម្ម:

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ០៤លើក សម័យប្រជុំពេញអង្គព្រឹទ្ធសភានីតិកាលទី៤ចំនួន០២លើក ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន ០៩ច្បាប់<br>- ប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៩ច្បាប់។ | - បានចាត់ចែងនីតិវិធី ឯកសារពាក់ព័ន្ធ ធ្វើកំណត់ហេតុសង្ខេប និងពិស្តារនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំពេញអង្គព្រឹទ្ធសភានីតិកាលទី៤<br>- បានសម្អាត តុបតែងសាល ផ្គត់ផ្គង់ និងផ្តល់សេវាភេសជ្ជៈ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំផ្សេងៗសរុបចំនួន០៩លើក មានអ្នកចូលរួមចំនួន៣៩៦នាក់<br>- បានថតចម្លងឯកសារចំនួន៥,៩២២ច្បាប់ អស់ក្រដាសចំនួន៤៩,៨៤៩សន្លឹក<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន២៣លើក |



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

| | |
|---|---|
| | - បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង និងកម្លាំងអន្តរាគមន៍ពីខាងក្រៅស្ថាប័នចំនួន១៣២នាក់ ស្មើនឹង១១លើក<br>- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០៩ច្បាប់ពីរដ្ឋសភា និងបានចាត់ចែងតាមនីតិវិធី<br>- បានធ្វើកំណត់បង្ហាញលើព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកាអម សេចក្តីសម្រេច និងលិខិតផ្សេងៗចំនួន៣១ច្បាប់<br>- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីម្រេច ប្រកាស ដីកាអម និងលិខិតផ្សេងៗចំនួន២៣៣ច្បាប់ ពីក្រសួង ស្ថាប័ននានា និងចាត់ចែងតាមនីតិវិធី<br>- បានសិក្សាស្រាវជ្រាវ និងធ្វើឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ចំនួន០៧ច្បាប់<br>- បានស្រាវជ្រាវ បកប្រែ និងសង្ខេបព័ត៌មានសភាអន្តរជាតិបានចំនួន៦០ច្បាប់<br>- បានរៀបចំទីកន្លែងប្រជុំ និងរៀបចំហ្វុងអក្សរប្រជុំពេញអង្គចំនួន០៦លើក ប្រចាំការថតសំឡេងថតវីដេអូ និងរៀបចំប្រព័ន្ធសំឡេងចំនួន០២លើក<br>- បានថត និងផ្សព្វផ្សាយព័ត៌មាន សេចក្តីជូនដំណឹងសេចក្តីប្រកាសព័ត៌មានចំនួន៣១លើក។ |

**២.មុខងារតំណាង:**

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា៖<br>+ អញ្ជើញចូលរួមប្រារព្ធព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម ថ្វាយសម្តេចព្រះមហាក្សត្រីនរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតា | - រៀបចំបែបបទ ផ្តល់សេវា អមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ចូលរួមក្នុងកិច្ចប្រជុំ និងជាគណៈអធិបតីក្នុងពិធីផ្លូវការផ្សេងៗសរុបចំនួន៣៣៧លើក |

| | |
|---|---|
| ជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល គម្រប់៨២ យាងចូល៨៣ ព្រះវស្សា នៅព្រះរាជដំណាក់សិរីមង្គល ព្រះបរមរាជវាំង<br>+ អញ្ជើញជាអធិបតីក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមា សម្ពោធឆ្លងព្រះវិហារ និងសមិទ្ធផលនានា នៅវត្តសារាយអណ្ដែត និងវត្តប្រាំបីមុំ ពិធីសម្ពោធឧបដ្ឋានសាលា និងសំណង់ផ្សេងៗក្នុងវត្តចំការខ្សាច់ ពិធីអភិសេកព្រះពុទ្ធរូបលើព្រះវិហារ រាប់បាត្រព្រះសង្ឃ១០៨អង្គ កាត់ឫសសីមាព្រះវិហារ និងពិធីបញ្ចុះបឋមសីលាបើកការដ្ឋានសាងសង់អគារពាណិជ្ជកម្ម និងសណ្ឋាគារស្កាយម៉ោនជិនវ៉ូ នៅខេត្តតាកែវ ខេត្តព្រះសីហនុ និងរាជធានីភ្នំពេញ<br>+ អញ្ជើញចូលរួមពិធីបុណ្យគម្រប់ខួប៣ឆ្នាំ និង៩ឆ្នាំ ដើម្បីឧទ្ទិសកុសល ជូនចំពោះដួងវិញ្ញាណក្ខន្ធសម្ដេចអគ្គមហាធម្ម-ពោធិសាល ជា ស៊ីម អតីតប្រធានព្រឹទ្ធសភា និងលោកជំទាវ ញ៉ែម សឿន ជាស៊ីម<br>+ អញ្ជើញជាអធិបតីនៃទិវាកុមារអន្តរជាតិ ០១មិថុនា ស្ដីពី ការលើកកម្ពស់សិទ្ធិកុមារ នៅមជ្ឈមណ្ឌលបុរីកុមារមិត្តភាពបារាំង-ហុងគ្រី ខេត្តតាកែវ<br>+ អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខ និងចែកអំណោយ ព្រមទាំងដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត មកពីសហ-រដ្ឋអាមេរិកទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅខេត្តកណ្ដាល និង | - បានផ្ដល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនងក្នុងការចុះបេសកកម្មអមដំណើរក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ និងទី៨ អញ្ជើញអមដំណើរជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ចុះស្រាវជ្រាវប្រមូលព័ត៌មាន និងជួបសំណេះសំណាល សាកសួរសុខទុក្ខកម្មកររោងចក្រ និងសិស្សា-នុសិស្ស ព្រមទាំងកម្មវិធីផ្សេងៗ នៅខេត្តកណ្ដាល និងខេត្តតាកែវ<br>- បានរៀបចំទីកន្លែងសម្រាប់កិច្ចប្រជុំ និងពិធីផ្សេងៗចំនួន០៩លើក<br>- បានផ្ញើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៤២នាក់ ស្មើនឹង៤១ច្បាប់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភាចំនួន០៣រូប ស្មើនឹង០៣ច្បាប់<br>- បានថតចម្លងឯកសារបានចំនួន៩៦៥ច្បាប់ អស់ក្រដាសចំនួន៦,០៥១សន្លឹក<br>- បានផ្ដល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន១៧៣នាក់ ស្មើនឹង៧០លើក<br>- បានទទួលលិខិតចូលចំនួន៩៩៣ច្បាប់<br>- បានផ្ដល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន១០៧លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់ |

| | |
|---|---|
| ខេត្តតាកែវ<br>- ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន ០៥ករណី ផ្ញើកំណត់បង្ហាញទៅក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន០៥ករណី ព្រមទាំងបានទទួលពាក្យបណ្តឹងជូនជ្រាបចំនួន ១៥ករណី និងឆ្លើយតបទៅម្ចាស់បណ្តឹង ចំនួន០៥ករណី<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះតាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញ ទូទាំងប្រទេសចំនួន២២៣លើក ដើម្បីជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយ វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាព សិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន១០២លើក។ | ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន៣០នាក់ ស្មើនឹង០៤លើក<br>- បានចូលរួមគោរពវិញ្ញាណក្ខន្ធសពចំនួន០២លើក<br>- បានចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន ០៧នាក់<br>- ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចូលរួមជាសមាជិកគាំទ្របរិច្ចាគថវិកា ជូនមូលនិធិគន្ធបុប្ផាកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- បានផ្តល់អត្ថបទព័ត៌មាន និងរូបថតចំនួន ១,១៣៩សន្លឹក ជូនអង្គភាពចំណុះអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា<br>- បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅចំនួន៩៤នាក់ អនុញ្ញាតឱ្យខ្ចីសៀវភៅចំនួន៣៨ក្បាល និងសងវិញចំនួន៤៤ក្បាល<br>- បានទទួលឯកសារ សៀវភៅ ព្រឹត្តិបត្រ ទស្សនាវដ្តី និងកាសែត ពីអង្គការ ស្ថានទូត ក្រសួង ស្ថាប័ន គ្រឹះស្ថានអប់រំ សប្បុរសជន អង្គភាពចំណុះអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៨៧ច្បាប់<br>- កំពុងរៀបចំផលិតសៀវភៅនិនានុលេខន៍ និងសៀវភៅបត់ស្តីពី ព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៩<br>- បានរៀបចំទស្សនាវដ្តីប្រចាំខែឧសភា ឆ្នាំ២០១៨<br>- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភាចំនួន៩៣លើក<br>- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន៥២លើក |

| | |
|---|---|
| | - បានសម្របសម្រួលទទួលដំណើរទស្សនកិច្ចសិក្សានៅព្រឹទ្ធសភាចំនួន០២លើក របស់សាស្ត្រាចារ្យ និងនិស្សិត មកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសាកលវិទ្យាល័យអាស៊ីអឺរ៉ុបចំនួន១៨នាក់ ។ |

**៣.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :**

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បានទទួលជួបសម្តែងការគួរសម និងជួបសវនាការ ជាមួយសមាជិកព្រឹទ្ធសភានៃសាធារណរដ្ឋបារាំង ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រថៃ និងឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋកូរ៉េ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា<br>- ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា បានទទួលជួបសម្តែងការគួរសម ជាមួយគណៈប្រតិភូសភាប្រឹក្សានយោបាយប្រជាជនចិន<br>- សមាជិកព្រឹទ្ធសភា បានអនុញ្ញាតឱ្យក្រុមប្រឹក្សាភិបាល Khmer Sight Foundation និងមន្ត្រីស្ម័គ្រចិត្ត និងកម្មសិក្សាថ្មីនៃការិយាល័យប្រហ្វង់កូហ្វូនី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ<br>- សមាជិកព្រឹទ្ធសភា បានអញ្ជើញចូលរួមមហាសន្និបាតប្រចាំឆ្នាំលើកទី៦ នៃបណ្តាញពិភពលោកការិយាល័យថវិកាសភា (GN-PBO) នៅប្រទេសកាណាដា ចូលរួមប្រជុំប្រចាំឆ្នាំលើកទី១ របស់ក្រុមប្រឹក្សាពិគ្រោះយោបល់អាយប៉ា(AIPA)ស្តីពី គ្រោះថ្នាក់គ្រឿងញៀន | - បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជននយោបាយ អង្គទូត និងអង្គការអន្តរជាតិនានា<br>- បានរៀបចំទីកន្លែងសម្រាប់ជំនួបសម្តែងការគួរសម និងសវនាការចំនួន០២លើក<br>- បានថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំជួបភ្ញៀវជាតិ និងអន្តរជាតិ មកបំពេញទស្សនកិច្ចនៅព្រឹទ្ធសភាចំនួន១៩លើក<br>- បានរៀបចំសម្អាត តុបតែងសាល និងផ្តល់សេវាភេសជ្ជៈ អាហារសម្រន់ និងផ្គត់ផ្គង់សម្ភារៈអនាម័យក្នុងកិច្ចប្រជុំចំនួន១១លើក ស្មើនឹង១៣៨នាក់<br>- បានថតចម្លងឯកសារចំនួន៨០ច្បាប់ អស់ក្រដាសចំនួន៩៦០សន្លឹក<br>- បានផ្តល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន៦៨នាក់ ស្មើនឹង២៥លើក<br>- បានធ្វើកំណត់បង្ហាញ កំណត់ហេតុ កំណត់ទូតសំណើ និងលិខិតឆ្លើយតបទៅក្រសួងផ្សេងៗ និងបណ្តាអង្គទូតនានាចំនួន២៦លើក<br>- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាន |

| | |
|---|---|
| (AIPACODD)នៅប្រទេសសិង្ហបុរី និងអញ្ជើញទៅបំពេញបេសកកម្មនៅព្រះរាជាណាចក្រជប៉ុន។ | ព្រឹទ្ធសភាចំនួន១២នាក់ ស្មើនឹង០៨ច្បាប់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន១៦លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន៦៧នាក់ ស្មើនឹង០៧លើក<br>- ថ្នាក់ដឹកនាំអគ្គលេខាធិការព្រឹទ្ធសភា បានជួបសវនាការ និងពិភាក្សាការងារ ជាមួយអគ្គលេខាធិការរដ្ឋសភានៃសាធារណរដ្ឋហ្វីលីពីន<br>- បានរៀបចំបែបបទជូនគណៈប្រតិភូសមាជិកព្រឹទ្ធសភា អញ្ជើញទៅបំពេញបេសកកម្ម និងចូលរួមកិច្ចប្រជុំ នៅក្រៅប្រទេសចំនួន០៣លើក<br>- បានរៀបចំបែបបទជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញទៅទស្សនកិច្ចសិក្សា ចូលរួមកិច្ចប្រជុំ និងសិក្ខាសាលាចំនួន១០លើក<br>- បានទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន និងបណ្ណាល័យនានា ដើម្បីសុំ និងទទួលសៀវភៅ ព្រឹត្តិបត្រ និងសម្រួលដល់កិច្ចការអន្តរជាតិ ដំណើរទស្សនកិច្ច សិក្ខាសាលា បេសកកម្មក្នុង និងក្រៅប្រទេស ស្នើសុំអាហារូបករណ៍វគ្គបណ្តុះបណ្តាល ព្រមទាំងការរៀបចំពិធីផ្សេងៗ។ |

**៤.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| | + បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៤១៥ច្បាប់<br>- បានវាយតម្លៃការអនុវត្តផែនការប្រតិបត្តិប្រចាំ |

| | |
|---|---|
| | ឆមាសទី១ ឆ្នាំ២០១៨<br>- រៀបចំចងក្រងសម្រង់ស្ថិតិ បទបង្ហាញ របាយ-ការណ៍ស្តីពី សកម្មភាពការងារព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំ**ខែមិថុនា និង** ឆមាសទី១ ឆ្នាំ២០១៨ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៩៤០ច្បាប់។<br>+ ការងារគ្រប់គ្រងបុគ្គលិកៈ<br>- បានរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន៤៦ច្បាប់<br>- ប្រជុំគណៈកម្មការស្តីពី ក្រមសីលធម៌មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានធ្វើបែបបទស្នើសុំគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទីភារកិច្ច នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងបញ្ចប់បទបញ្ជាផ្ទៃក្នុង ក្រមសីលធម៌សម្រាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។<br>+ ការងារបណ្តុះបណ្តាលធនធានមនុស្សៈ<br>- ការបណ្តុះបណ្តាលធនធានមនុស្សក្នុង និងក្រៅស្ថាប័នចំនួន១១វគ្គ មានសិក្ខាកាមសរុបចំនួន២៧៩នាក់។<br>+ ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈៈ<br>- បានប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- បានប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងស្តីពីគោលការណ៍ហិរញ្ញវត្ថុ សម្រាប់នីតិកាលទី៤ព្រឹទ្ធសភា និងសេចក្តីព្រាងគម្រោងថវិកា ឆ្នាំ២០១៩ |

| | |
|---|---|
| | ព្រឹទ្ធសភា ព្រមទាំងស្នើថវិកាបន្ថែមសម្រាប់ការងារចាំបាច់<br>- ប្រជុំបូកសរុបវាយតម្លៃលទ្ធផលស្តីពី ការងារសង្គមកិច្ច និងការផ្តល់សេវាប្រចាំខែ**មិថុនា និង**ឆមាសទី១ ឆ្នាំ២០១៨<br>- បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌ និងបុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់បៀវត្សប្រាក់បំណាច់ និងប្រាក់វិភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិប្រចាំខែ ព្រមទាំងធ្វើតារាងប្រាក់ឧបត្ថម្ភរបស់ថ្នាក់ដឹកនាំមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា ផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារផ្សេងៗ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំនានាចំនួន ២១សំណើ និងផ្គត់ផ្គង់សម្ភារៈអនាម័យ សម្ភារៈការិយាល័យ និងភេសជ្ជៈចំនួន៦១សំណើ សម្រាប់កិច្ចប្រជុំផ្សេងៗ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំសម្អាត តុបតែងសាល ផ្តល់សេវាភេសជ្ជៈ និងអាហារសម្រន់ ក្នុងពិធីផ្សេងៗចំនួន០៨លើក មានអ្នកចូលរួមចំនួន២៤៩នាក់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន២៨៨លើក<br>- បានថតចម្លងឯកសារចំនួន៥,៥១៥ច្បាប់ និងចងក្រងសៀវភៅចំនួន២២ក្បាល អស់ក្រដាសចំនួន២២,២២៦សន្លឹក និងជួសជុលសម្អាតម៉ាស៊ីន |

| | |
|---|---|
| | ថតចម្លងចំនួន១៥លើក<br>- បានផ្តល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន២៥នាក់ ស្មើនឹង១៥លើក។<br>+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តរឹង និងទន់ :<br>- រៀបចំគម្រោងស្នើសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលទី៤<br>- បន្តសាងសង់អគារថ្មី០១ខ្នងសម្រាប់ជាការិយាល័យធ្វើការបណ្តោះអាសន្ន និងបញ្ចប់ការសាងសង់ឃ្លាំងថ្មី នៅខាងក្រោយអគារ E<br>- ជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម បិទលេខកូដសម្ភារៈសារពើភ័ណ្ឌ និងបែងចែកកុំព្យូទ័រលើតុ សរុបចំនួន១៦៩គ្រឿង<br>- រៀបចំកែលម្អបរិស្ថានក្នុងបរិវេណព្រឹទ្ធសភា ឱ្យមានសោភ័ណភាពល្អ<br>- បន្តរៀបចំបំពាក់អំពូលប្រើដោយថាមពលព្រះអាទិត្យក្នុងបរិវេណព្រឹទ្ធសភា<br>- បានតាំងពិព័រណ៍រូបភាព និងចងបដា ពាក្យស្លោក ធ្វើហ្លុងអក្សរចំនួន០៥លើក<br>- សហការជាមួយក្រុមហ៊ុនកំចាត់សត្វកណ្តៀរ និងសហការប្រចាំការម៉ាស៊ីនភ្លើង នៅតាមសាលប្រជុំ ព្រមទាំងបានត្រួតពិនិត្យមើលការប្រើប្រាស់ទឹកភ្លើង ក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាក សរុបចំនួន៥៥លើក<br>- រៀបចំតបណ្តាញខ្សែកាបអុបទិកសម្រាប់ Live |

| | |
|---|---|
| | វីដេអូ ក្នុងកិច្ចប្រជុំសំខាន់ៗពីសាលប្រជុំពេញអង្គ ទៅសាលបណ្ណាល័យ ដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកសារព័ត៌មាន ផ្តិតយករូបភាព និងសម្លេងបានច្បាស់<br>- ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Connect Wifi និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និង Set up កម្មវិធីសរុបចំនួន៨១គ្រឿង។ បានUpload សេចក្តីជូនដំណឹង ព្រឹត្តិបត្រព័ត៌មានសុខភាព ទស្សនាវដ្តី និងរូបភាពសកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាសរុបចំនួន៦៩ចំណងជើង។<br>+ ការងារផ្សេងៗ :<br>- បានផលិតព័ត៌មានទាន់ហេតុការណ៍ និងផលិតខ្សែវីដេអូ សម្រាប់បង្ហោះលើ Alert Newsចំនួន ២០៤ប្រធានបទ<br>- ថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំក្នុងកម្មវិធីផ្សេងៗចំនួន៣៨លើក<br>- បានចុះបញ្ជីសៀវភៅ បោះត្រា បិទប័ណ្ណខ្ចី និងសងសៀវភៅ និងបញ្ជូនសៀវភៅដាក់នៅសាលអាន ព្រមទាំងជួសជុលឯកសារ និងសៀវភៅចាស់ៗ សរុបចំនួន២៤២ក្បាល<br>- បញ្ចូលទិន្នន័យសៀវភៅព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ច្បាប់ កាសែត ទស្សនាវដ្តី ព្រឹត្តិបត្រ រាជកិច្ច ដាក់លេខកូដសៀវភៅថ្មី និងបញ្ចូលសៀវភៅតាម E-Library បណ្តាញ Facebook សរុបចំនួន៦,៣៣៦ក្បាល។ |

## II.ទិសដៅការងារខែកក្កដា ឆ្នាំ២០១៨

**១.មុខងារនីតិកម្ម:**

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤។

**២.មុខងារតាមដានការអនុវត្តច្បាប់និងគោលនយោបាយនានា :**

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួង ស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញ។

**៣.មុខងារតំណាង :**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានា នៅតាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញ

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

-ត្រៀមរៀបចំកម្មវិធីសម្ពោធសមិទ្ធផលនៅខេត្តកំពង់ស្ពឺ និងខេត្តតាកែវ

-ត្រៀមទទួលមន្ត្រីរាជការ យុវជន សិស្ស និស្សិត និងសាធារណជនមកទស្សនកិច្ចនៅព្រឹទ្ធសភា។

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :**

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអង្គទូតនានា

-ត្រៀមទទួលដំណើរទស្សនកិច្ចរបស់អគ្គលេខាធិការព្រឹទ្ធសភានៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាទៅបំពេញបេសកកម្មក្រៅប្រទេស

-ការចូលរួមវេទិកា ALFOCOM និងវេទិកា APPF នាខែមករា ឆ្នាំ២០១៩ នៅខេត្តសៀមរាប

-ការចូលរួមមហាសន្និបាត APF និង ASGPF នាខែកក្កដា នៅទីក្រុងQuebec នៃប្រទេសកាណាដា

-ការចូលរួមមហាសន្និបាត AIPA នាខែកញ្ញា នៅសាធារណរដ្ឋសិង្ហបុរី

-ការចូលរួមមហាសន្និបាត IPU និង ASGP នាខែតុលា នៅទីក្រុងហ្សឺណែវ នៃប្រទេសស្វីស

-ត្រៀមទៅទស្សនកិច្ចផ្លូវការក្នុងឱកាសខួប៦០ឆ្នាំ នៃទំនាក់ទំនងការទូត នាខែតុលា នៅសាធារណរដ្ឋប្រជាមានិតចិន

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា

-ត្រៀមអនុវត្តន៍កម្មវិធីជាមួយ(APF)

-ត្រៀមចូលរួមវគ្គបណ្ដុះបណ្ដាលនានាដែលចាត់ចែងដោយវិទ្យាស្ថានសភាកម្ពុជា(PIC)។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន :**

-ត្រៀមបញ្ចប់ការកសាងអគារធ្វើការបណ្ដោះអាសន្ន០១ខ្នង

-ការងារតាមដានការសុំជំនួយពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន រួមមានការកសាងអគារសាលប្រជុំពេញអង្គថ្មី សម្ភារៈបរិក្ខារអេឡិចត្រូនិច និងរថយន្ត

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹកភ្លើង ការគ្រប់គ្រងការប្រើប្រាស់ Internet

-ការសិក្សារៀបចំ TV-online របស់ព្រឹទ្ធសភា និងបង្កើនការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការងារប្រចាំថ្ងៃ

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpageក្នុងកម្រិតអគ្គនាយកដ្ឋាន និងគណៈកម្មការ

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងបុគ្គលិកតាមប្រព័ន្ធព័ត៌មានវិទ្យា កសាង Program និង Software ដើម្បីអនុវត្តតាមអង្គភាព និងការបណ្តុះបណ្តាលក្នុងនោះចូលអនុវត្តកម្មវិធី Eបណ្ណាល័យ និង E បណ្ណសារ

-អនុវត្តគម្រោងបច្ចុប្បន្នភាពរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាតាមតម្រូវការថ្មី

-សិក្សាអំពីការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធតួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ចាប់ផ្តើមការសិក្សាអំពីការបង្កើតអគ្គនាយកដ្ឋានស្រាវជ្រាវ និងអគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិ បម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ទំនាក់ទំនងជាថ្មីជាមួយភាគីវៀតណាម ដើម្បីបន្តអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ICT) និងការបំពាក់សម្ភារៈបរិក្ខារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ដំណាក់កាលទី២)

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍ពីប្រទេសផ្សេងៗទៀត ឆ្នាំ២០១៨

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការ

-ការពារគម្រោងថវិកាឆ្នាំ២០១៩ របស់ព្រឹទ្ធសភា ជាមួយក្រុមបច្ចេកទេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រៀមការពារកម្រិតនយោបាយ

-ត្រៀមរបាយការណ៍ទូទាត់ថវិកាចំណាយឆមាសទី១ ឆ្នាំ២០១៨ ព្រឹទ្ធសភា ជូនគណៈកម្មាធិការអចិន្ត្រៃយ៍

-ត្រៀមរៀបចំផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល(២០១៩-២០២១) និងថវិកាតាមកម្មវិធី ឆ្នាំ២០១៩។

### III.សេចក្តីសន្និដ្ឋាន

ខែមិថុនានេះជាខែដែលមានការរវល់ខ្ពស់ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មលើសេវាទ្រទ្រង់មុខងារនីតិកម្ម មុខងារតំណាង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិកសមាជិកាព្រឹទ្ធសភា បានដោយរលូនៗ ជាពិសេសត្រូវត្រៀមគ្រប់លក្ខណៈសម្បត្តិ ដើម្បីផ្តល់សេវាឱ្យបានកាន់តែប្រសើរ និងគ្រប់តាមតម្រូវការចាំបាច់សមស្របនឹងតម្រូវការថ្មីៗ ជាអាទិភាពៗ ចំពោះមុខងារ

អភិវឌ្ឍន៍ស្ថាប័ន បានបន្តយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍធនធានមនុស្ស បង្កើនសមត្ថភាពស្រាវជ្រាវ ភាសាបរទេសកាន់តែមានតម្រូវការធំជាងមុនដែលត្រូវខិតខំឆ្លើយតបឱ្យបានល្អប្រសើរ។ ការប្រើប្រាស់ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីៗ ដើម្បីធានាបាននូវសេវាគ្រប់ប្រភេទប្រកបដោយគុណភាពខ្ពស់ជូន អតិថិជនរបស់ខ្លួន។ ចំណែកការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានបន្តយុទ្ធនាការស្វែងរកការគាំទ្រ និងជំនួយពីប្រភពក្នុង និងក្រៅប្រទេសសម្រាប់បម្រើឱ្យព្រឹទ្ធសភា នីតិកាលទី៤ ដំណើរការកាន់តែល្អប្រសើរ។ ព្រឹទ្ធសភា នីតិកាលទី៤ ត្រូវដើរតួជំនួសមុខអង្គការនីតិប្បញ្ញត្តិកម្ពុជាក្នុងក្របខ័ណ្ឌ AIPA, APF និង IPU នាពេលខាងមុខ។

ដំណើរការព្រឹទ្ធសភា នីតិកាលទី៤ ទាមទារឱ្យអនុវត្តន៍បានប្រសើរជាងមុន នូវនីតិវិធីកសាង របាយការណ៍ពិនិត្យច្បាប់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងជូនសម័យប្រជុំពេញអង្គ និងប្រុងប្រយ័ត្ន អំពីអក្ខរាវិរុទ្ធ ឃ្លាឃ្លោង ព្រមទាំងមុខសញ្ញាដែលត្រូវសម្តែងគារវកិច្ច នៅក្នុងរបាយការណ៍ទាំងនោះ។

គ្រប់យន្តការបានដំណើរការ និងកសាងជាបណ្តើរៗនូវផែនការយុទ្ធសាស្ត្រប្រចាំនីតិកាលទី៤ និងកម្មវិធីការងារប្រចាំឆ្នាំ ឆមាស ត្រីមាស និងប្រចាំខែ ដើម្បីអនុវត្តន៍ថវិកាកម្មវិធីឱ្យបានល្អប្រសើរ។៚

ថ្ងៃសុក្រ ៩រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨

**អគ្គលេខាធិការស្តីទី**

ឡោក_សាយ